# មេរៀនទី ១១៣: ព្រះយេស៊ូវបានប្រទានព្រះពរដ៏ពិត

## ម៉ាថាយ ៥:១-១២

**គោលបំណង៖** ព្រះសព្វព្រះទ័យអស់អ្នកដែលបន្ទាបខ្លួន។

**ខគម្ពីរចងចាំ៖ ម៉ាថាយ ៥:៣** *"មានពរហើយ អស់អ្នកដែលមានសេចក្តីកំសត់ខាងឯវិញ្ញាណ ដ្បិតនគរស្ថានសួគ៌ជារបស់ផងអ្នកទាំងនោះ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ព្រះយេស៊ូវបានធ្វើការអធិប្បាយនៅពីមុខហ្វូងមនុស្សជាច្រើន ប៉ុន្តែទ្រង់បានប្រាប់ទិសដៅនៃព្រះពរដល់អ្នកដើរតាមទ្រង់។ ការដើរតាមព្រះយេស៊ូវមានតម្លៃ ហើយក៏មានរង្វាន់ដ៏អស្ចារ្យដែរ។ សូមអានព្រះគម្ពីរ **ម៉ាថាយ ៥:១-១២** សារឡើងវិញ។ តើព្រះពរមួយណាដែលបានកើតឡើងពិតនៅក្នុងជីវិតរបស់អ្នក? តើពរពិតមួយណាដែលអ្នកចង់ឲ្យព្រះយេស៊ូវជួយធ្វើឲ្យកើតមានយ៉ាងពិតប្រាដកនៅក្នុងជីវិតអ្នក? ព្រះយេស៊ូវចង់ឲ្យការទាំងនេះជាអ្នកប្រាប់ដល់អ្នក។ ទ្រង់នឹងផ្តល់ឲ្យអ្នកនូវជំនួយគ្រប់យ៉ាងដែលអ្នកចង់បាន។

**ចំរៀង៖** ១. ខ្ញុំដឹងថា ២. គឺជាការល្អ ៣. ចូរបន្ទាបខ្លួននៅចំពោះព្រះអង្គ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «រាប់ផ្លែឈើ»

**សម្ភារៈដែលត្រូវការ៖** ក្រដាស និងខ្មៅដៃ

១. ចែកកុមារជា ៣ ឬ ៤ក្រុម ហើយឲ្យក្រដាស និងខ្មៅដៃទៅក្រុមនីមួយៗ។

២. ឲ្យកុមារគ្រប់ក្រុមទាំងអស់សរសេរឈ្មោះផ្លែឈើទាំងអស់ ដែលពួកគេស្គាល់ក្នុងរយៈពេល២នាទី។




៣. បន្ទាប់មកគ្រូប្រមូលក្រដាសទាំងអស់ពីគ្រប់ក្រុម ហើយធ្វើការរាប់ក្រុមណាដែលអាចសរសេរឈ្មោះ បានច្រើនជាងគេក្រុមនោះជាអ្នកឈ្នះ។

៤. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា យើងមិនអាចចងចាំផ្លែឈើទាំងអស់ដែលព្រះបានបង្កើតនោះទេ។ ក៏ដូចគ្នានេះ ដែលយើងមិនអាចរាប់ព្រះពរដែលព្រះបានប្រទានឲ្យដល់យើងអស់នោះទេ។

### ៤. ការណែនាំមេរៀន

តើអ្នកនឹងធ្វើដូចម្តេចពេលដែលដើរជួបគ្រូរបស់អ្នកនោះ? នៅពេលអ្នកទៅលេងផ្ទះយាយតា តើអ្នកធ្វើដូម្តេច? ចុះនៅពេលមានចាស់ទុំមកលេងផ្ទះ តើអ្នកនឹងធ្វើដូចម្តេច? តើអ្នកមានអាកប្បកិរិយាបែបណា នៅពេលដែលអ្នក

និយាយជាមួយមិត្តភក្តិរបស់អ្នក? តើអ្នកធ្វើខ្លួនជាមេគេ ឬក៏អ្នកបន្ទាបខ្លួននិងធ្វើល្អជាមួយគេ? ចុះនៅពេលដែលអ្នកនិយាយជាមួយតាយាយរបស់អ្នក? តើអ្នកបន្ទាបខ្លួនដាក់ពួកគាត់ ឬក៏អ្នកឈ្លើយជាមួយពួកគាត់? ថ្ងៃនេះយើងនឹងរៀបពីអាកប្បកិរិយាដ៏សំខាន់ ដែលយើងគួរធ្វើដើម្បីឲ្យយើងអាចទទួលរង្វាន់នៅឯនគរឋានសួគ៌។

## ៥. រឿងនៅក្នុងព្រះគម្ពីរ

(ព្រីនក្រដាសហត្ថកម្ម និងប្រើវាដើម្បីប្រាប់ពីរឿងនៅក្នុងព្រះគម្ពីរថ្ងៃនេះ)

រឿងនៅក្នុងព្រះគម្ពីររបស់យើងនៅថ្ងៃនេះ គឺដកស្រង់ចេញពីផ្នែកមួយនៅក្នុងព្រះគម្ពីរ ដែលនិយាយអំពីព្រះពរដ៏ពិតប្រាកដ។ នៅក្នុងខគម្ពីរទាំងនោះ ព្រះយេស៊ូវនិយាយអំពីអាកប្បកិរិយា ដែលយើងគួរធ្វើតាមលំដាប់លំដោយដើម្បីឲ្យព្រះសព្វព្រះទ័យ។ ព្រះក៏បានបង្រៀនពួកយើងប្រសិនបើយើងមានអាកប្បកិរិយាល្អទាំងអស់នោះ នោះយើងនឹងទទួលបានរង្វាន់នៅឯនគរឋានសួគ៌។ ដូច្នេះ វាពិតជាមានសារៈសំខាន់ណាស់ ដែលយើងត្រូវតែយល់ពីអាកប្បកិរិយាទាំងប្រាំបីនោះ។

១. ឲ្យកុមារកាត់រង្វង់មូលចេញមកហើយនិយាយថា “ មានពរហើយ......”

២. កាត់ពាក្យ “ដែលមានសេចក្តីកំសត់ខាងឯវិញ្ញាណ” និងពន្យល់ពួកគេថាវាមានន័យថា ការដែលបន្ទាបខ្លួនដោយគិតពីអ្នកដទៃមុន និងមិនអួតខ្លួន។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

៣. កាត់ពាក្យ “ដែលយំសោក” និងពន្យល់ពួកគេថាវាមានន័យថា នៅពេលដែលអ្នកកើតទុក្ខព្រះនឹងការពារអ្នក។ ហើយវាគឺជាការពិតដ៏ពិសេសនៅពេលដែលយើងកើតទុក្ខ ចំពោះអ្នកដែលមិនជឿលើព្រះនោះ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

៤. កាត់ពាក្យ “ដែលស្លូតត្រង់” និងពន្យល់ពួកគេថាវាមានន័យថា ការដែលចេះអត់ធ្មត់ ដោយមិនមានការខឹងចំពោះអ្នកដទៃ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

៥. កាត់ពាក្យ “ដែលស្រេកឃ្លាននូវសេចក្តីសុចរិត” និងពន្យល់ពួកគេថាវាមានន័យថា ធ្វើតែអ្វីដែលត្រឹមត្រូវជាមួយព្រះ និងស្តាប់ព្រះទ័យទ្រង់។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

៦. កាត់ពាក្យ “ ដែលមានចិត្តមេត្តាករុណា” និងពន្យល់ពួកគេថាវាមានន័យថា បង្ហាញពីសន្តានចិត្តល្អសម្រាប់អ្នកដទៃ ជំនួសឲ្យការវាយតម្លៃលើពួកគេ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

៧. កាត់ពាក្យ “ដែលមានចិត្តបរិសុទ្ធ” និងពន្យល់ពួកគេថា វាមានន័យថា គឺមានតែដួងចិត្តដែលធ្វើឲ្យព្រះសប្បាយព្រះទ័យ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

៨. កាត់ពាក្យ “ដែលផ្សះផ្សាគេ” និងពន្យល់ពួកគេថាវាមានន័យថា ធ្វើខ្លួនឲ្យល្អ ដោយមានសន្តិភាពជាមួយនឹងមនុស្សគ្រប់គ្នា ដោយមិនមានការឈ្លោះប្រកែកគ្នា ឬក៏ភាពអាត្មានិយមនោះឡើយ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

៩. កាត់ពាក្យ“ដែលត្រូវគេបៀតបៀន” និងពន្យល់ពួកគេថា វាមានន័យថាយើងអាចទទួលរងនូវការធ្វើបាបពីអ្នកដ៏ទៃដោយព្រោះយើងស្រលាញ់ព្រះបម្រើព្រះ ប៉ុន្តែយើងនៅតែបន្តសេចក្តីស្រលាញ់របស់យើងចំពោះព្រះ។ ឥឡូវបិតវាភ្ជាប់ជាមួយរង្វង់។

ឥឡូវនេះអ្នកមានផ្កាមួយទង!

នៅពេលដែលយើងបន្ទាបខ្លួននៅចំពោះព្រះនោះយើងនឹងទទួលបាននូវពរដ៏ពិតប្រាដក។ ផ្នែកមួយនៃភាពជាមនុស្សគឺយើងត្រូវស្វែងយល់ថា តើអ្វីដែលព្រះទ្រង់សព្វព្រះទ័យ និងយល់ពីទំនាក់ទំនងរបស់យើងជាមួយទ្រង់។ ព្រះគម្ពីរបានប្រាប់យើងថាព្រះបានបង្កើតផែនដីនេះ ហើយទ្រង់គឺជាព្រះទ្រង់បានសោយរាជ្យជាស្តេចនៃឋានសួគ៌។ ព្រះយេស៊ូវគឺជាព្រះដ៏បរិសុទ្ធ និងជាព្រះសុចរិត។

ប្រសិនបើយើងឃើញគំរូរបស់នរណាម្នាក់ នោះវាគឺពិតជាងាយស្រួលខ្លាំងមែនទែន ដែលធ្វើឲ្យយើងមានមោទនភាពចំពោះខ្លួនឯង និងមិនបន្ទាបខ្លួននោះ។ ប៉ុន្តែប្រសិនបើយើងមើលឃើញពីគំរូរបស់ព្រះយេស៊ូវនោះ យើងនឹងងាយស្រួលក្នុងការបន្ទាបខ្លួន ពីព្រោះព្រះយេស៊ូវគឺសប្បុរស និងបន្ទាបខ្លួន បើទោះបីជាទ្រង់ជាព្រះដ៏មានព្រះចេស្តាក៏ដោយ។ នៅពេលដែលយើងមានសេចក្តីសប្បុរស សេចក្តីស្រលាញ់ និងពេញដោយសេចក្តីមេត្តាករុណា នោះយើងនឹងមិនសូវជាខ្វល់ខ្វាយពីភាពសំខាន់សម្រាប់ខ្លួននោះទេ។ គឺយើងខ្វល់ខ្វាយសម្រាប់អ្នកដទៃ។ នេះគឺជាឧទាហរណ៍នៃការសុភាព ឬការបន្ទាបខ្លួន។ ប្រសិនបើដួងចិត្តរបស់យើងចេះបន្ទាបចុះនោះអាកប្បកិរិយារបស់យើងក៏ធ្វើបានត្រឹមត្រូវ ហើយយើងអាចស្រលាញ់អ្នកជុំវិញយើងបាន។

## ៦. សំនួរពិភាក្សា

១. តើពរដ៏ពិតទាំងអស់មានប៉ុន្មាន? *ប្រាំបី*

២. តើនរណាជាគំរូដ៏ល្អដែលជួយយើង ដើម្បីឲ្យយើងអាចបន្ទាបខ្លួនបាន?

*ព្រះយេស៊ូវគឺជាម្នាក់ដែលសុចរិតនិងបន្ទាបខ្លួន ទោះបីជាទ្រង់ជាព្រះដ៏មានព្រះចេស្តាក៏ដោយ*

៣. សូមមើលទៅផ្កានៃពរពិតរបស់អ្នក។ តើអ្នកគិតថាផ្នែកណាមួយដែលអ្នកគិតថាពិបាកថែរក្សាជាងគេ?

*ទុកឲ្យកុមារជាអ្នកឆ្លើយ*

## ៧. ល្បែងកំសាន្ត «ដណ្តើមក្រដាសពណ៌»

**សម្ភារៈដែលត្រូវការ៖** ៣ ឬ ៤ សន្លឹកនៃក្រដាសពណ៌ខុសៗគ្នា




១. គ្រូត្រូវកាត់ក្រដាសពណ៌នោះ ជារាងតូចៗហើយបិតវានៅកណ្តាលថ្នាក់រៀន។

២. នៅពេលដែលគ្រូនិយាយថា “១ ២ ៣ ទៅ” ហើយសិស្សត្រូវរត់ទៅយកក្រដាសមួយពណ៌។

៣. បន្ទាប់ពីយកក្រដាសបានហើយ កុមារដែលចាប់បានក្រដាសពណ៌ដូចគ្នាត្រូវរត់រកគ្នា។

៤. ក្រុមណាមានគ្នាច្រើនជាគេក្រុមនោះជាអ្នកឈ្នះ។

៥. កុមារដែលឈ្នះត្រូវដើរទៅរកកុមារដែលចាញ់ហើយនិយាយ ថា “ឯងធ្វើបានល្អហើយ”

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា មនុស្សខ្លះប្រឈមមុខនឹងការបៀតបៀនកាន់តែច្រើន ហើយអ្នកខ្លះប្រឈមមុខនឹងការបៀតបៀនតិចជាងមុន ប៉ុន្តែយើងត្រូវតែបន្តនូវការចេះបន្ទាបខ្លួននេះ ពីព្រោះវាធ្វើឲ្យព្រះសព្វព្រះទ័យ។

**៨. ខគម្ពីរចងចាំ** **ម៉ាថាយ ៥:៣**

**៩. ហត្ថកម្ម** **«ពរដ៏ពិត»**

**សម្ភារៈដែលត្រូវការ៖** ព្រីនក្រដាសហត្ថកម្ម និងកូល័រ

សូមធ្វើតាមការណែនាំរឿងនៅក្នុងព្រះគម្ពីរដើម្បីធ្វើផ្កានៃព្រះពរដ៏ពិត។

សូមឲ្យកុមារតុបតែងនិងផាត់ពណ៌ផ្កានៃព្រះពរដ៏ពិតនោះ។



**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ពរដ៏ពិត

ដែលមានសេចក្ដីកំសត់
ខាងវិញ្ញាណ

ដែលយំសោក

ដែលស្លូតត្រង់

ដែលស្រេកឃ្លាននូវ
សេចក្ដីសុចរិត

ដែលមានចិត្តមេត្តាករុណា

ដែលមានចិត្តបរិសុទ្ធ

ដែលផ្សះផ្សាគេ

មានពរហើយ...

ដែលត្រូវគេបៀតបៀន

